CHURCH WORLD SERVICE

**អង្គការស៊ីដាប់បែលយូអេសកម្ពុជា** បានបំពេញបេសកកម្មនៅក្នុងប្រទេសកម្ពុជាចាប់តាំងពី ឆ្នាំ ១៩៧៩។ បច្ចុប្បន្ននេះ អង្គការបានអនុវត្តកម្មវិធី អភិវឌ្ឍន៍សហគមន៍ ទឹកស្អាតនិងអនាម័យ ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងការកសាងសមត្ថភាពដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ធ្វើការនៅតំបន់ជនបទដាច់ស្រយាលក្នុងខេត្តចំនួន ៣ គឺ ៖ ខេត្តព្រះវិហារ កំពង់ធំ និងបាត់ដំបង ។ ពេលនេះយើងខ្ញុំត្រូវការជ្រើសរើសបុគ្គលិក**ស្ត្រី** ចំនួន **២ រូប** មានតួនាទីជា:

## បុគ្គលិកអភិវឌ្ឍន៍សហគមន៍ (Community Development Worker)

### (មានមូលដ្ឋាននៅ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ)

បៀវត្សគោលចន្លោះពី: $ 4,264- $ 6,565 ក្នុង១ឆ្នាំ និងមានអត្ថប្រយោជន៍បន្ថែមផ្សេងៗទៀត

**ភារកិច្ច និងទំនួលខុសត្រូវចំបង:**

- ធ្វើការជាមួយក្រុមប្រឹក្សាឃុំ គណ:កម្មាធិការអភិវឌ្ឍន៍ភូមិ (VDC) និងជនបង្គោលដើម្បីលើកកំពស់សេដ្ឋកិច្ចសង្គម និងសេដ្ឋកិច្ចគ្រួសាររបស់ប្រជាជនក្រីក្រនៅតាមជនបទធ្វើការសំរបសំរួល និងរៀបចំបណ្តាញការងារ ព្រមទាំងគៀងគរប្រមូល**ធនធាន**សហគមន៍សំរាប់ការងារអភិវឌ្ឍន៍ សហគមន៍
- លើកទឹកចិត្តឱ្យមានការចូលរួមពីស្ត្រី និងជនទីទ័លក្រក្នុងការធ្វើសេចក្តីសំរេចចិត្ត ការកំណត់បញ្ហា ការវិភាគ និងគំនិតផ្តួចផ្តើម ក្នុងការដោះស្រាយបញ្ហាអាទិភាពចំបងៗ
- ជួយដល់ក្រុមប្រឹក្សាឃុំ គណ:កម្មាធិការអភិវឌ្ឍន៍ភូមិ (VDC) និងអង្គការសហគមន៍មូលដ្ឋាន (CBOs) ក្នុងការរៀបចំបង្កើតផែនការអភិវឌ្ឍន៍ភូមិ និងធានាថា ពួកគាត់បានអនុវត្ត និងត្រួតពិនិត្យ
- កសាងទំនាក់ទំនង និងទំនុកចិត្តជាមួយប្រជាជននៅសហគមន៍ រួមទាំងលើកទឹកចិត្តអ្នកទទួលផលអោយចូលរួម ក្នុងការធ្វើសេចក្តីសំរេចចិត្ត

**តំរូវការ គុណវឌ្ឍន៍:**

- ត្រូវមានសញ្ញាបត្រ័តុទិយភូមិ (មានបទពិសោធន៍ទាក់ទងនឹងអភិវឌ្ឍន៍សហគមន៍កាន់តែប្រសើរ)
- មានបទពិសោធន៍យ៉ាងតិច ២ ឆ្នាំ ជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងការងារអភិវឌ្ឍន៍សហគមន៍
- មានចំណេះដឹងយ៉ាងតិច ១ ឆ្នាំ ទាក់ទងនឹង វិស័យ សុខភាព សុវត្ថិភាពស្បៀង ការចិញ្ចឹមជីវិត ឥណទាន និងការរកប្រាក់ចំណូល ឬផ្នែកពាក់ព័ន្ធផ្សេងៗ
- មានឆន្ទ:ធ្វើការជាក្រុម (Team) ។ អាចស្នាក់នៅភូមិ ៥ យប់ក្នុងមួយសប្តាហ៍ និងធ្វើការ៤សប្តាហ៍ក្នុង ១ខែ តែសម្រាកសងវិញមួយសប្តាហ៍
- មានសមត្ថភាព រៀបចំកម្មវិធីបណ្តុះបណ្តាល និងមានជំនាញសំរបសំរួល
- មានសមត្ថភាព រៀបចំសហគមន៍
- មានអត្តចរិក ចរិយាសម្បត្តិល្អ និងមានសមត្ថភាពកសាងទំនាក់ទំនងជាមួយប្រជាជននៅតាមសហគមន៍
- អាចធ្វើការដោយឯករាជ្យ ដោយត្រូវការ ការគ្រប់គ្រងតិចតួច
- អាចយល់ និងទំនាក់ទំនងជា ភាសាអង់គ្លេស

បេក្ខនារីមានចំណាប់អារម្មណ៍សូមផ្ញើ ពាក្យសុំបំរើការងារ ភ្ជាប់មកជាមួយទំរង់ស្នើសុំបំរើការងាររបស់អង្គការស៊ីដាប់បែលយូអេស រួមទាំងប្រវត្តិរូបសង្ខេបថ្មីមកអាសយដ្ឋាន ផ្ទះលេខ ៤៣ ផ្លូវ ១១២ សង្កាត់ផ្សារដេប៉ូ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬ ផ្ញើទៅកាន់អ៊ីម៉ែល job@cwscambodia.org ឬការិយាល័យគំរោងព្រះវិហារ ភូមិជាំក្សាន្ត ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ឬ នៅគំរោងកំពង់ធំ ផ្ទះលេខ ៦៨ ផ្លូវដីរីជាន់ខ្លា សង្កាត់ផ្លូវដីរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ មិនឱ្យហួសពីថ្ងៃទី **០៩ ខែ កុម្ភៈ ឆ្នាំ ២០១២**។ សូមចូលគេហទំព័រ www.cwscambodia.org ឬការិយាលយ័របស់អង្គការសំរាប់តារាងពិពណ៌នាការងារ និងទំរង់ពាក្យស្នើសុំបំរើការងារ ។ មានតែបេក្ខនារីដែលជាប់សំភាសន៏ដំបូង (short-listed) ប៉ុណ្ណោះដែលនឹងទំនាក់ទំនងសំរាប់សំភាសន៏ ។

**រាល់ពាក្យសុំបំរើការងារទាំងអស់ នឹងត្រូវរក្សាទុកជាការសំងាត់ ។**

**អង្គការស៊ីដាប់បែលយូអេសកម្ពុជា ជាអង្គការដែលគោរពតាមគោលនយោបាយការការពារកុមារយ៉ាងតឹងរ៉ឹងបំផុត ។**